**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលព្រៃឈើ**
**នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**

ភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០១៤

**ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV/REL)**
**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**តាមរយៈ:** ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) លើកទី១៣។

**ជូនភ្ជាប់:** -បញ្ជីវត្តមាន..................................................................................................ចំនួន១ច្បាប់
-របៀបវារៈនៃកិច្ចប្រជុំ.........................................................................................ចំនួន១ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេសវាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV/REL) បានរៀបចំកិច្ចប្រជុំលើកទី១៣ នៅសណ្ឋាគារ អ៊ីមផារៀល ហ្គាដិន វីឡា រាជធានីភ្នំពេញ ដែលទទួលបានលទ្ធផល ដូចខាងក្រោម៖

**១.សមាសភាពចូលរួម**

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ១៤ នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

-ស្ថាប័នរាជរដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងរ៉ែ និងថាមពល និងក្រសួងមហាផ្ទៃ

-ទីប្រឹក្សាអន្តរជាតិៈ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ(FAO)។

**២.គោលបំណងនៃអង្គប្រជុំ**

គោលបំណងនៃអង្គប្រជុំគឺ៖

- ពិភាក្សាលើនិងនិតិវិធីការងារផ្នែករដ្ឋបាលរបស់ក្រុមការងារ (MRV/ REL)
- បន្តពិភាក្សាលើចំណាត់ថ្នាក់គម្របព្រៃឈើ និង គម្របដី សម្រាប់អនុវត្តកម្មវិធីរេដ
- ពិនិត្យលើខ្លឹមសារនៃឯកសារសុំពន្យាលទ្ធភាព នៃការគាំទ្រថវិការបស់FAO-UN-REDD និងពិនិត្យលើរបាយការណ៍នៃការអភិវឌ្ឍនសកម្មភាពក្រុមការងារ MRV/ REL កន្លងមក

**៣.ដំណើរការកិច្ចប្រជុំ**

- ក្រុមការងារបានធ្វើការពិភាក្សាលើកិច្ចដំណើរ ការងាររដ្ឋបាលរបស់ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV/REL) ។ ជាពិសេសពិភាក្សាលើនិតិវិធីនៃការរៀបចំកិច្ចប្រជុំ និងរបាយការណ៍។ នារាល់កិច្ចប្រជុំលើកក្រោយ អង្គប្រជុំស្នើសុំអោយក្រុមលេខាធិការក្រុមការងារ MRV/REL ធ្វើការរាយការណ៍សង្ខេបអំពីលទ្ធផល នៃប្រជុំលើកមុនជូនក្រុមការងារ និងស្នើសុំអោយលេខាធិការ MRV/REL ធ្វើការចែកចាយរបាយការណ៍ជូនគ្រប់ សមាជិកក្រុមការងារ MRV/REL បន្ទាប់ពីរៀបចំរួច។

- អង្គប្រជុំបានបន្តធ្វើការពិភាក្សាលើលទ្ធផលចំណាត់ថ្នាក់គម្របព្រៃឈើនិងគម្របដីនៃកិច្ចប្រជុំMRV/REL លើកទី១២ នាខេត្តព្រះសីហនុ ។ ដែលលទ្ធផលនៃកិច្ចប្រជុំនោះ មានចំណាត់ថ្នាក់ចំនួន ០៤ មិនទាន់សម្រេច មានដូចជាចំណាត់ថ្នាក់៖

| ល.រ | ចំណាត់ថ្នាក់ | អនុចំណាត់ថ្នាក់ | ផ្សេងៗ |
|---|---|---|---|
| ១ | ដីស្រែ (Paddy Field) | វាលស្រែប្រើទឹកភ្លៀង (Rain Feed) | ពិភាក្សាលើ អនុចំណាត់ថ្នាក់ |
| | | វាលស្រែប្រើប្រព័ន្ធស្រោចស្រព (Irrigate) | |
| ២ | ព្រៃស្រល់ (Pine Tree) | ព្រៃស្រល់ធម្មជាតិ (Natural Pine) | ពិភាក្សាលើ អនុចំណាត់ថ្នាក់ |
| | | ព្រៃស្រល់ដាំ (Pine Plantation) | |
| ៣ | ព្រៃដុះឡើងវិញ(Regrowth Forest) | | ពិភាក្សាផ្នែក បច្ចេកទេសបន្ត |
| ៤ | តំបន់ដីសើម (Wetland) | | ពិភាក្សាផ្នែក បច្ចេកទេសបន្ត |

- បន្ទាប់មក លោក **Mathieu Van Rijn** (FAO) បានធ្វើបង្ហាញអំពីសំណើសុំពន្យាលទ្ធភាពនៃការគាំទ្រថវិការបស់ UN-REDD ដែលគ្រោងនឹងយកទៅធ្វើបទបង្ហាញក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិកម្មវិធី ដើម្បីផ្តល់ការសម្រេច ក្នុងនេះមានហេតុផល ៤យ៉ាង នៃការសុំពន្យាលទ្ធភាពនៃការគាំទ្រថវិកា ក្នុងរយៈពេល៦ខែ សម្រាប់បន្តអនុវត្តការងារ MRV/REL រួមមានសម្រាប់៖

- ផ្ទៀងផ្ទាត់លទ្ធផលផែនទីគោល ឆ្នាំ ២០១៣/២០១៤ ដោយប្រើប្រាស់ High Resolution image និងទិន្នន័យប្រមូលមកពីទីវាល ដើម្បីបង្កើតផែនទីបម្រែបម្រួលគម្របព្រៃឈើ និងគម្របដី ដែលជាបច្ចុប្បន្នភាពទិន្នន័យគោលសម្រាប់ប៉ាន់ប្រមាណកាបូនស្តុកលើកទីមួយ
- បង្កើតកម្រិតបំភាយយោងគោល ក្នុងលក្ខខណ្ឌជាតិ (National Circumstance)
- បង្កើតសមីការលូតលាស់ និងកត្តាបំភាយសម្រាប់ប្រភេទព្រៃលិចទឹកនៅកម្ពុជា
- រៀបចំរបាយការណ៍ការប្រើប្រាស់ដី តាមគោលនយោបាយ និងអភិបាលកិច្ចព្រៃឈើ សម្រាប់គាំទ្រកម្មវិធី UN-REDD ដែលជាសូចនាករយ៉ាងសំខាន់សម្រាប់យុទ្ធសាស្ត្ររេដកម្ពុជា។

បន្ទាប់មកទៀតលោក **Mathieu Van Rijn** (FAO) បានធ្វើបង្ហាញស្តីពីផែនការសកម្មភាព MRV/REL ដែលត្រូវអនុវត្តបន្តនៅក្នុងត្រីមាសទី៣ និងទី៤ នៃឆ្នាំ២០១៤ និងត្រីមាសទី១ និងទី២ ឆ្នាំ២០១៥ បង្ហាញពីសេចក្តីសង្ខេបពីវឌ្ឍនភាពការងារនៃ Outcome 4 ដែលបទបង្ហាញនេះនឹងត្រូវបង្ហាញក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិកម្មវិធី (PEB) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៤ ខាងមុខ។

## ៤.លទ្ធផលនៃកិច្ចប្រជុំ

### ៤.១ ពិភាក្សាលើការងាររដ្ឋបាលរបស់ក្រុមការងារ (MRV/ REL)

ក្នុងការអនុវត្តបែបបទការងាររដ្ឋបាល អង្គប្រជុំបានសម្រេចអោយក្រុមលេខាធិការ MRV/REL រៀបចំរបាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំ មានលក្ខណៈស្របគ្នារវាងក្រុមការងារ MRV/REL និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) ដោយកំណត់ពេលមួយសប្តាយទៅ១០ថ្ងៃ ក្រោយពេលប្រជុំម្តងៗ។

**៤.២ បន្តពិភាក្សាលើចំណាត់ថ្នាក់គម្របព្រៃឈើ និង គម្របដី សម្រាប់អនុវត្តរេដ**

អង្គប្រជុំសម្រេចរក្សាចំណាត់ថ្នាក់មេ (Main Class) នៅដដែលចំនួន២០ និងឯកភាពអោយមាន អនុចំណាត់ថ្នាក់ពីរគឺ ព្រៃស្រល់ធម្មជាតិ (Natural Pine) និងព្រៃស្រល់ដាំ (Pine Plantation)។ ចំពោះចំណាត់ថ្នាក់តំបន់ដីសើម (Wetland) អង្គប្រជុំសម្រេចអោយ សមាជិក MRV/REL តំណាងក្រសួងបរិស្ថាន ធ្វើការទាក់ទងអ្នកបច្ចេកទេសតំបន់ដីសើម (Wetland) ដើម្បីស្វែងយល់បន្ថែម និងស្វែងរកឯកសារពាក់ព័ន្ធ ដើម្បីពិភាក្សាបច្ចេកទេសលម្អិតលើចំណាត់ថ្នាក់នេះនៅពេលក្រោយ។

**៤.៣ ពិភាក្សាលើលក្ខខណ្ឌនៃការសុំពន្យាលទ្ធភាព នៃការគាំទ្រថវិការបស់ FAO-UN-REDD**

អង្គប្រជុំបានធ្វើការពិនិត្យ និងផ្តល់មតិទៅលើឯកសារសុំពន្យាលទ្ធភាព នៃការគាំទ្រថវិកា និងរបាយការណ៍នៃការអភិវឌ្ឍនសកម្មភាពក្រុមការងារ MRV/ REL កន្លងមក លើចំណុចខ្លះដូចជាៈ

- បង្ហាញអោយច្បាស់អំពីយុទ្ធសាស្រ្តកម្មវិធីរេដនៅកម្ពុជា
- សកម្មភាពអនុវត្តបន្តរបស់ក្រុមការងារ MRV/REL
- បង្ហាញអំពីលទ្ធផលនៃចំណាត់ថ្នាក់គម្របព្រៃឈើ និងគម្របដីដែលបានពិភាក្សាគ្នាកន្លងមក

## ៥.ទិសដៅអនុវត្តបន្ត

-ក្រុមការងារនឹងបន្តរៀបចំកិច្ចប្រជុំពិភាក្សាលើចំណាត់គម្របព្រៃឈើ និងគម្របដី ក្នុងគោលបំណងពិភាក្សាសម្រេចលើចំណាត់ថ្នាក់តំបន់ដីសើម មុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច

-ពិភាក្សាលើសកម្មភាពចំបងៗ ដែលមានក្នុងផែនការសកម្មភាពរបស់ក្រុមការងារ MRV/REL និងកំណត់អ្នកទទួលខុសត្រូវ

-រៀបចំកិច្ចប្រជុំក្រុមការងារ MRV/REL លើកទី១៤ ខាងមុខ ចំពោះពេលវេលា និងទីកន្លែង ក្រុមការងារលេខាធិការនឹងធ្វើការជម្រាបជូនសមាជិកពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយអនុគ្រោះតាមការគួរ ។

លេខ………………….នពស

បានឃើញ និង បញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

"សូមមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះ "

ភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**

# រូបថតសកម្មភាពនៃកិច្ចប្រជុំ MRV លើកទី១៣



